# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)

## កិច្ចប្រជុំលើកទី 16

26 កញ្ញា 2024

ទីតាំង៖ មហាវិទ្យាល័យសហគមន៍តំបន់ North Shore នៅទីក្រុង Lynn មានទីតាំង
ស្ថិតនៅ 300 Broad Street, Lynn, MA, 01901។
ម៉ោង 6:30 ល្ងាច ដល់ 8:00 យប់

## <u>កំណត់ហេតុកិច្ចប្រជុំ</u>

ទីកន្លែងប្រជុំ៖ ផ្ទាល់

ឯកសារកិច្ចប្រជុំ៖ របៀបវារៈ ស្លាយ

សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន៖

- Madeline Fraser Cook
- Marcos Luna (ផ្ទាល់)
- Peter Maathey
- Patricia Spence
- Jen Salinetti
- Kalila Barnett (ផ្ទាល់)
- Melissa Ferretti
- Sofia Owen (ផ្ទាល់)

បុគ្គលិកការិយាល័យប្រតិបត្តិថាមពលនិងកិច្ចការបរិស្ថាន (EEA) ដែលមានវត្តមាន៖

- María Belén Power អនុរដ្ឋលេខាក្រុមប្រឹក្សា EJC (ផ្ទាល់)
- Caroline Lemoine អនុប្រធាន EEA
- Jonathan Guzman ប្រធាន EEA (ផ្ទាល់)

បុគ្គលិកនាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត ដែលមានវត្តមាន៖

- Tom O'Shea ជាស្នងការ
- Stephanie Cooper ជាអនុរដ្ឋលេខាធិការយុត្តិធម៌បរិស្ថាន

អ្នកចូលរួមសំខាន់ៗផ្សេងទៀត៖

- Nicholson ជាអភិបាលក្រុង
- Crighton ជាសមាជិកព្រឹទ្ធសភា
- Daniel Cahill ជាអ្នកតំណាង

1. **មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ**

   Kecil John បានជម្រាបជូនពីទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ រួមទាំងការប្រើប្រាស់ប្រអប់សំណួរនិងចម្លើយ (Q&A) និងលទ្ធភាពអាចទទួលបានអ្នកបកប្រែផ្ទាល់មាត់។ María Belén Power បានស្វាគមន៍អ្នកចូលរួមទាំងអស់។

2. **ទិដ្ឋភាពទូទៅនៃរបៀបវារៈ**

**María Belén Power** បានរំលឹកឡើងវិញអំពីរបៀបវារៈនៃកិច្ចប្រជុំ។

3. **ការហៅឈ្មោះសមាជិក/ការអនុម័តលើកំណត់ហេតុប្រជុំពីមុន**

   **María Belén** បានធ្វើការហៅឈ្មោះសមាជិកក្រុមប្រឹក្សា EJC។ នៅពេលចាប់ផ្តើមកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សាដូចខាងក្រោមបានមានវត្តមានចូលរួម។ **Kalila Barnett, Madeline Fraser Cook, Melissa Ferretti, Marcos Luna, Peter Maathey, Sofia Owen, Jen Salinetti, Patricia Spence**.

   សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមិនមានវត្តមានចូលរួម៖ **Cheryll Holley, Caroline Hon, Namrita Kapur, Lydia Lowe, Ari Zorn, និង Miles Gresham។**

   **María Belén** បើកឱកាសឱ្យមានការដាក់ជូនសំណើដើម្បីអនុម័តលើកំណត់ហេតុពីកិច្ចប្រជុំលើកមុន។ **Marcos Luna** បានស្នើសុំឱ្យយល់ព្រម។ **Patricia Spence** បានគាំទ្រសំណើ។ រាល់សមាជិកក្រុមប្រឹក្សាដែលមានវត្តមានទាំងអស់បានទទួលយកកំណត់ត្រា លើកលែង **Sofia Owen** មិនបានបោះឆ្នោតគាំទ្រ ដោយសារតែមិនបានចូលរួមកិច្ចប្រជុំពីមុន។

   **មតិស្វាគមន៍របស់អភិបាលក្រុងលោក Nicholson**
   អភិបាលក្រុងលោក Nicholson បានស្វាគមន៍វត្តមានអ្នកចូលរួម និងសម្តែងការអរគុណដល់ EJC។ អភិបាលក្រុងលោក Nicholson បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការផ្តល់អាទិភាពចំពោះយុត្តិធម៌បរិស្ថាន និងអនាម័យនៃតំបន់ឆ្នេរ King's Beach។

   **មតិស្វាគមន៍សមាជិកព្រឹទ្ធសភាលោក Crighton**
   សមាជិកព្រឹទ្ធសភាលោក Crighton បានពិភាក្សាអំពីការសម្រេចចិត្តលើការប្រើប្រាស់ដីធ្លីក្នុងប្រវត្តិសាស្ត្រដែលបាននាំទៅរកផលប៉ះពាល់ផ្នែកបរិស្ថាននិងសុភាពសាធារណៈ រួមទាំងគំនិតផ្តួចផ្តើមឧស្សាហកម្មដែលនាំមកនូវអត្រាកើនឡើងនៃជំងឺហឺត និងជំងឺបេះដូង។ សមាជិកព្រឹទ្ធសភាលោក Crighton បានសង្កត់ធ្ងន់លើសារៈសំខាន់នៃរដ្ឋបាលរបស់ Healey Driscoll ដើម្បីធានាបាននូវការបង្កើតប្រព័ន្ធដឹកជញ្ជូនដែលងាយប្រើប្រាស់បាន និងល្អសម្រាប់បរិស្ថាន មានដូចខ្សែរថភ្លើង Fairmont ជាដើម។

   **មតិស្វាគមន៍របស់អ្នកតំណាងលោក Cahill**
   Cahill ជាអ្នកតំណាង បានស្វាគមន៍អ្នកចូលរួម និងថ្លែងអំណរគុណដល់ EJC ។ Cahill ជាអ្នកតំណាង បានបញ្ជាក់ពីភាពចាំបាច់ដែលត្រូវយល់ដឹងថា បញ្ហាបរិស្ថានប៉ះពាល់ទាំងតំបន់ទីក្រុង និងទីជនបទ។

4. **វគ្គសំណួរនិងចម្លើយជាសាធារណៈលើកទីមួយ**
   ទាំងសាធារណៈជនចូលរួមតាមអនឡាញនិងដោយផ្ទាល់ សុទ្ធតែបានផ្តល់មតិយោបល់ សំណួរ និងស្នើសុំ។
   - អ្នកចូលរួមតាមអនឡាញម្នាក់ ដែលជាអ្នកចូលរួមខាងផ្នែកព្រៃឈើនៃទីក្រុង Lynn បានសង្កត់ធ្ងន់លើសារៈសំខាន់នៃសមភាពព្រៃឈើ និងគម្របព្រៃឈើនៅទីក្រុង Lynn។ អ្នកចូលរួមបានចែករំលែកគេហទំព័ររបស់ខ្លួន www.lynnincommon.com/urban-forestry ដែលរួមបញ្ចូលទាំងព័ត៌មានស្តីពីគំនិតផ្តួចផ្តើមបច្ចុប្បន្នរបស់ពួកគេផងដែរ។
   - អ្នកចូលរួមដោយផ្ទាល់ បានស្នើឱ្យប្រើប្រាស់កសិដ្ឋានថាមពលពន្លឺព្រះអាទិត្យសហគមន៍ជាជម្រើសសន្សំថាមពលដែលងាយស្រួលប្រើប្រាស់ និងមានតម្លៃសមរម្យសម្រាប់សមាជិកសហគមន៍ដែលរស់នៅក្នុងអាផាតមិន។

5. **បទបង្ហាញរបស់នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត**
វាគ្មិនគឺ**លោកស្នងការ Tom O'Shea** បានផ្តល់បទបង្ហាញអំពីគោលដៅជីវចម្រុះ និងផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានសម្រាប់រដ្ឋម៉ាសាជូសិត។ លោក Tom បានបកស្រាយពន្យល់ថា យុត្តិធម៌បរិស្ថានត្រូវបានកំណត់ថាជាស្នូលនៃការងារដែលកំពុងដំណើរការនៅនាយកដ្ឋាន រួមទាំងបានដាក់បញ្ចូលនៅក្នុងផែនការយុទ្ធសាស្ត្រប្រាំឆ្នាំថ្មីដែលគ្របដណ្តប់ទៅលើផ្នែកជីវចម្រុះ អាកាសធាតុ និងយុត្តិធម៌បរិស្ថាន។ លោក Tom បានផ្តល់គោលដៅយុត្តិធម៌បរិស្ថានសម្រាប់នាយកដ្ឋានមានដូចជា ការពង្រឹងសមត្ថភាព ការលើកកម្ពស់សមធម៌ ការកែលម្អលទ្ធភាពទទួលបានភាពរីករាយនឹងធម្មជាតិ និងការរក្សាបានទំនាក់ទំនងស៊ិចង្វាក់គ្នាជាមួយក្រុមកុលសម្ព័ន្ធ។ លោក Tom បានផ្តល់ទិដ្ឋភាពទូទៅនៃបទបញ្ជាប្រតិបត្តិលេខ 618 ដែលបង្កើតគោលដៅជីវចម្រុះ រួមទាំងការគ្រប់គ្រងនិងការការពារទីជម្រក ការស្តារប្រព័ន្ធអេកូឡូស៊ី និងការផ្សារភ្ជាប់អ្នករស់នៅជាមួយនឹងធម្មជាតិ។

សមាជិកក្រុមប្រឹក្សាបានសាកសួរអំពីការសម្របសម្រួលរវាងនាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត និងអង្គភាពផ្សេងទៀតដោយសារលក្ខណៈនៃបទបញ្ជាប្រតិបត្តិ និងបានថ្លែងអំណរគុណដល់លោកស្នងការចំពោះការងារដែលកំពុងដំណើរការ។

វាគ្មិនជា**អនុរដ្ឋលេខាធិការបរិស្ថានលោក Stephanie Cooper** បានបកស្រាយពន្យល់អំពី**ចំណុចអាទិភាព**របស់នាយកដ្ឋាន**នៅទីក្រុង Lynn**។ លោក Stephanie បានពិភាក្សាអំពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការស្តារធម្មជាតិឡើងវិញជាច្រើនដែលកើតឡើងនៅក្នុងទីក្រុង រួមមាន ឧទ្យាន Lynn Harbor Park តំបន់ឆ្នេរ King's Beach ផ្លូវ Northern Strand Trail ឧទ្យាន Lynn Heritage State Park និងផែនេសាទ DCR Willis Fishing Pier។

សមាជិកក្រុមប្រឹក្សាបានសាកសួរអំពីការថែទាំរយៈពេលវែង ស្តង់ដាអនាម័យជាប្រវត្តិសាស្ត្រ និងដំណើរការតាមដានការបែងចែកមូលនិធិតាមតំបន់ភូមិសាស្ត្រ។

6. **វគ្គសំណួរ និងចម្លើយសាធារណៈលើកទី 2**
ទាំងអ្នកចូលរួមតាមអនឡាញនិងដោយផ្ទាល់ សុទ្ធតែបានផ្តល់មតិយោបល់ និងសំណូមពរ។ អ្នកចូលរួមពីមកពីទីក្រុង Salem និងទីក្រុង Taunton បានលើកទឹកចិត្តឱ្យ EJC ធ្វើទស្សនកិច្ចទៅកាន់ទីក្រុងនិងស្ថាប័នរបស់ពួកគេ។

**មតិយោបល់ពីសំណួរនិងចម្លើយ មានរៀបរាប់ដូចខាងក្រោម**

| # | សំណួរ | ឈ្មោះអ្នកសួរ | ចម្លើយ |
|---|---|---|---|
| **1** | ខ្ញុំជាសមាជិកក្រុមប្រឹក្សាតំណាងទីក្រុង Lynn ហើយខ្ញុំចង់ដឹងថាតើមានជំនួយបច្ចេកទេសតាមមូលដ្ឋានជាមួយផ្តល់ជូនទីក្រុងដើម្បីជួយដល់ដំណើរឆ្ពោះទៅរកការកែលម្អតាមរយៈគំនិតផ្តួចផ្តើមបរិស្ថាននេះដែរឬទេ? ជាពិសេស តើគំនិតផ្តួចផ្តើមជាមួយនឹងថាមពលខ្យល់ ឬថាមពលពន្លឺព្រះអាទិត្យ ដូចគ្នានឹង | Nicole McClain | នឹងផ្តល់ព័ត៌មានបន្ថែមតាមអ៊ីមែល |

| | | | |
|---|---|---|---|
| | គម្រោងដែលមាននៅទីក្រុង Salem ដែរឬទេ? | | |

7. **ជំហានបន្ទាប់ និងការលើកវារកាល**
   **María Belén** បានរំលឹកសមាជិកក្រុមប្រឹក្សាអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំបន្ទាប់នៅ**ថ្ងៃទី 14 ខែវិច្ឆិកា នៅទីក្រុង Taunton** ។ លើសពីនេះទៀត **Sofia Owen** បានសាកសួរអំពីស្ថានភាពនៃកិច្ចប្រជុំក្រុមការងារ។ **María Belén** នឹងចាត់វិធានការបន្ថែមទៀត ដោយសារតែការរឹតបន្តឹងច្បាប់កិច្ចប្រជុំសាធារណៈ។ **María Belén** បានស្វាគមន៍ការផ្តល់យោបល់ពី EJC សម្រាប់ប្រធានបទកិច្ចប្រជុំនាពេលអនាគត។ **Melissa Ferretti** បានស្នើឱ្យគណៈកម្មការកិច្ចការជនជាតិដើមភាគតិចណ្ណាធ្វើការពិភាក្សាអំពីយុទ្ធសាស្ត្រ EJ កុលសម្ព័ន្ធ ចំណែកឯ **Jen Salinetti** បានណែនាំឱ្យកំណត់អាទិភាពនៃបញ្ហា និងពិនិត្យឡើងវិញលើការសម្រេចចុងក្រោយលើនិយមន័យ EJ ដោយឱ្យទីភ្នាក់ងារជាអ្នកទទួលខុសត្រូវ។ **María Belén** បានជំរុញឱ្យសមាជិកក្រុមប្រឹក្សាក្នុងការបង្កើតអាទិភាពនីមួយៗដាច់ដោយឡែកក្នុងគោលបំណងកំណត់អាទិភាពរួមចុងក្រោយដើម្បីសម្រេចគោលដៅ។

**María Belén** បានស្នើសុំផ្អាកការប្រជុំ។ **Patricia Spence** បានស្នើសុំផ្អាកការប្រជុំ។ **Melissa Ferretti** បានគាំទ្រ។ កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង **8:03** យប់។